**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ១១.០៤៩/០៧ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

# ការដោះស្រាយបណ្តឹងរបស់ គ.ជ.ប ទាក់ទងនឹងទម្រង់ ១០២៥

បណ្តឹងតវ៉ារបស់តំណាងគណបក្សសម រង្ស៊ី ទាក់ទងទៅនឹងទម្រង់ ១០២៥ (ឈ្មោះត្រៀមលុបចេញពីបញ្ជីបោះឆ្នោត) ចំនួន ៤៧ បណ្តឹង ត្រូវបាន គ.ជ.ប យកមកដោះស្រាយ ក្នុងនោះបណ្តឹងចំនួន ២១ បណ្តឹង ត្រូវបានធ្វើជាលិខិតឆ្លើយតបទៅដើមបណ្តឹង និងចំនួន២៦ បណ្តឹងទៀត ឯកភាពតាមការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

បណ្តឹងចំនួន ២១ បណ្តឹងដែល គ.ជ.ប ធ្វើលិខិតឆ្លើយតបនោះ ត្រូវបានតំណាងគណបក្សសម រង្ស៊ី ប្តឹងតវ៉ាទៅនឹងការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ចំពោះការរក្សាទុកឈ្មោះចំនួន **៩៥.៤៧៨ នាក់** នៅក្នុងទម្រង់ ១០២៥ មិនត្រឹមត្រូវតាមនីតិវិធី និងការណែនាំរបស់ គ.ជ.ប ។ បណ្តឹងនេះមាននៅក្នុងខេត្តកណ្តាលចំនួន ១ ឃុំ និងក្រុងភ្នំពេញចំនួន ២០ សង្កាត់ ។ តាមការស្រាវជ្រាវជាក់ស្តែងរបស់ គ.ជ.ប ចំនួនឈ្មោះដែលមាននៅក្នុងបណ្តឹងទាំង ២១ នេះ មានឈ្មោះតែចំនួន **៤៧.៤១៩ នាក់** ប៉ុណ្ណោះ ហើយក្នុងចំនួននេះក្រុមប្រឹក្សាឃុំ សង្កាត់ បានលុបចេញចំនួន **២.៣៧១ នាក់** ពីទម្រង់ ១០២៥ រួចហើយ (គឺរក្សាទុកឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតដដែល) ហើយ គ.ជ.ប សម្រេចលុបចេញបន្ថែមទៀតចំនួន **២៦.១៨០ នាក់** ពីទម្រង់១០២៥(គឺរក្សាទុកឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតដដែល) និងរក្សាទុកឈ្មោះក្នុងទម្រង់នេះចំនួន **១៨.៨៦៨ នាក់** (ឈ្មោះត្រៀមលុបចេញពីបញ្ជីបោះឆ្នោត) ។

ចំណែក ២៦ បណ្តឹងទៀត ត្រូវបានតំណាងគណបក្សសម រង្ស៊ី ប្តឹងតវ៉ាទៅនឹងការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដូចខាងលើដែរ ប៉ុន្តែបណ្តឹងនេះ គ.ជ.ប មិនយកមកដោះស្រាយទេ ហើយបានធ្វើជាលិខិតឆ្លើយតបទៅដើមបណ្តឹងវិញ ។ នៅក្នុងលិខិតឆ្លើយតបដែលចេញផ្សាយនៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ សរសេរថា " បន្ទាប់ពីបានទទួលបណ្តឹងរបស់គណបក្សសម រង្ស៊ី គ.ជ.ប បានធ្វើការស្រាវជ្រាវ និងពិនិត្យផ្ទៀងផ្ទាត់យ៉ាងយកចិត្តទុកដាក់រួចមក ឃើញថា ការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ លើបញ្ជីទម្រង់បែបបទលេខ ១០២៥ ធ្វើឡើងដោយមានឯកសារ និងភស្តុតាងសំអាងគ្រប់គ្រាន់ ។ ដូច្នេះ គ.ជ.ប មិនអាចយកបណ្តឹងនេះមកដោះស្រាយបានទេ" ។ បណ្តឹងនេះ មាននៅខេត្តកំពង់ស្ពឺ ចំនួន១ឃុំ ខេត្តកណ្តាល ចំនួន ១ឃុំ និងក្នុងក្រុងភ្នំពេញចំនួន ២៤ សង្កាត់ ។